**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានឯកអគ្គរាជទូតកម្ពុជា**
**ប្រចាំប្រទេសជប៉ុន**

# សេចក្តីជូនដំណឹង
## ចំពោះអ្នកដំណើរទៅកាន់ប្រទេសកម្ពុជាដោយឆ្លងកាត់ប្រទេសថៃ

ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសជប៉ុន សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ អ្នកដំណើរបរទេស និងពលរដ្ឋខ្មែរ ដែលធ្វើដំណើរទៅកាន់ព្រះរាជាណាចក្រកម្ពុជា បានជួបប្រទះការលំបាកយ៉ាងខ្លាំង ក្នុងពេលធ្វើដំណើរឆ្លងកាត់តាមអាកាសយានដ្ឋានក្នុងប្រទេសថៃ រួមទាំងនៅទីក្រុងបាងកក ដែលការលំបាកទាំងនោះ មានដូចជា៖

- មានការសាកសួរសំណួររយៈពេលជាច្រើនម៉ោង
- ការទាមទារហួសហេតុឱ្យបង្ហាញឯកសារបញ្ជាក់ពីធនធានហិរញ្ញវត្ថុ
- បរិយាកាសគួរឱ្យធុញថប់ និងរងការសង្ស័យដោយមិនសមហេតុផល
- ករណីខ្លះ មានការបាត់វ៉ាលីឥវ៉ាន់របស់អ្នកដំណើរដែលត្រូវបញ្ជូនបន្តពីប្រទេសថៃទៅកាន់ប្រទេសកម្ពុជា។

ដើម្បីចៀសវាងជួបប្រទះការលំបាកខាងលើ អ្នកដំណើរត្រូវបានណែនាំយ៉ាងម៉ឺងម៉ាត់ ជៀសវាងការធ្វើដំណើរឆ្លងកាត់ប្រទេសថៃជាបណ្តោះអាសន្ន និងការប្រើប្រាស់ក្រុមហ៊ុនអាកាសចរណ៍ថៃ រហូតដល់មានការជូនដំណឹងបន្ថែម។ អ្នកដំណើរក៏ត្រូវបានលើកទឹកចិត្តឱ្យធ្វើការពិចារណាជ្រើសរើសក្រុមហ៊ុនអាកាសចរណ៍ផ្សេង ដែលផ្តល់ភាពងាយស្រួលជាង និងលក្ខខណ្ឌអំណោយផលក្នុងការធ្វើដំណើរឆ្លងកាត់។

ព្រះរាជាណាចក្រកម្ពុជា នៅតែជាគោលដៅសុវត្ថិភាព និងផ្តល់ការស្វាគមន៍ដល់អ្នកដំណើរទាំងអស់។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
តូក្យូ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh